ក្រសួងអប់រំយុវជននិងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់នៃការប្រើប្រាស់ ខេអេចឃ្យូអរ ធនាគារជាតិ

THE IMPORTANCE OF USING KHQR NATIONAL BANK

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

# ក្រសួងអប់រំយុវជននិងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់នៃការប្រើប្រាស់ ខេអេចឃ្យូអរ ធនាគារជាតិ

# THE IMPORTANCE OF USING KHQR NATIONAL BANK

**គ្រូណែនាំ៖ ហុង កែវដារ៉ា**

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២**
**ប្រធានបទ៖ សារៈសំខាន់នៃការប្រើប្រាស់ ខេអេចឃ្យូអរ ធនាគារជាតិ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ហុង កែវដារ៉ា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃនិងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យនៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យគឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យ ហិរញ្ញវត្ថុនិងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយ ផ្លូវនិស្សិតឱ្យយល់ច្បាស់ពី ការអនុវត្តន៍ការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការការបញ្ចប់ និងត្រួតពិនិត្យវាយតម្លៃព្រមទាំងផ្តល់ ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**សារៈសំខាន់នៃការប្រើប្រាស់ខេអេចយូអរ ធនាគារជាតិ**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការផ្តល់ឥណទាន របស់ធនាគារ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



ឡូត ឡៃអូន
ID: B22/2087



ឡេង រចនា
ID: B22/1198



ហ៊ីត គឹមស្រុង
ID: B22/1239



ជា ចរិយា
ID: B22/1020



ផេង សូរិយ៉ា
ID: B22/2607

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យវ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **ហុង កែវដារ៉ា** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាងដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។ សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ " សារៈសំខាន់នៃការប្រើប្រាស់ ខេអេចឃ្យូអរ ធនាគារជាតិ " នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



ឡូត ឡៃអូន

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា បានធ្វើឱ្យមានការកកើតនូវការអនុវត្តន៍និងការប្រើប្រាស់ប្រព័ន្ធ KHQR ដើម្បីជំរុញការទូទាត់ប្រាក់តាមទូរស័ព្ទដោយមិនចាំបាច់ប្រើសាច់ប្រាក់ក្នុងដៃ ឬប័ណ្ណធនាគារ។ KHQR បានរួមបញ្ចូលគ្នារវាងធនាគារផ្សេងៗនិងស្ថាប័នហិរញ្ញវត្ថុជាច្រើនដែលមានគោលបំណងធ្វើឱ្យការទូទាត់សាច់ប្រាក់កាន់តែមានប្រសិទ្ធភាព ធ្វើឱ្យការប្រើប្រាស់ប្រព័ន្ធឌីជីថលកាន់តែងាយស្រួល ជួយឱ្យប្រជាជនមានទំនាក់ទំនងផ្នែកហិរញ្ញវត្ថុតាមរយៈបច្ចេកវិទ្យា វិស័យអាជីវកម្មរវាងអាជីវករ និងអតិថិជនធ្វើប្រតិបត្តិការទូទាត់បានរហ័ស ដោយមិនចាំបាច់គិតថ្លៃសេវាខ្ពស់ ។

ឈរលើមូលដ្ឋាន ដែលជាកត្តាក្នុងការស្រាវជ្រាវ និងចងក្រងសារណាមួយនេះឡើង គឺដើម្បីស្វែងយល់នៅចំណុចសំខាន់ខ្លះៗនៃការបង្កើតប្រព័ន្ធ KHQR ឡើងរបស់ធនាគារជាតិ កម្ពុជា ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយពាក់ព័ន្ធទៅលើវិស័យបច្ចេកវិទ្យា ទៅកាន់អ្នកប្រើប្រាស់ជំនាន់ក្រោយឱ្យស្គាល់ច្បាស់ពីសារៈសំខាន់។ ជាក់ស្តែងសម្រាប់ក្រុមយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ ទាក់ទងទៅនឹងការប្រើប្រាស់ប្រព័ន្ធ KHQR របស់ធនាគារជាតិនៃកម្ពុជា ដែលក្រុមយើងខ្ញុំសង្ឃឹមថា ការសិក្សាស្រាវជ្រាវមួយនេះ នឹងបានផ្តល់ជាចំណេះដឹងនិងអត្ថប្រយោជន៍មួយចំនួនដល់អ្នកដែលមានបំណងចង់ស្វែងយល់អំពីការប្រើប្រាស់ KHQR របស់ធនាគារជាតិនៃកម្ពុជា។ ក្នុងនោះទៀតសោត ក្រុមយើងខ្ញុំបានយល់ដឹងទាក់ទិនទៅនឹងចំណុចមួយចំនួន ដូចជាប្រវត្តិរបស់ធនាគារ ការបង្កើតឡើងនូវប្រព័ន្ធ KHQR បេសកកម្ម ទស្សនវិស័យ គោលដៅ រចនាសម្ព័ន្ធរបស់ធនាគារជាតិ ស្ថានភាពទូទៅរបស់ធនាគារនិងសារៈសំខាន់នៃការប្រើប្រាស់ KHQR។ KHQR ពិតជាមានប្រជាប្រិយភាពឈានមុខគេ ក្នុងការបម្រើសេវាកម្មប្រកបដោយទំនុកចិត្ត សុវត្ថិភាព ជាពិសេស KHQR ជួយឱ្យបំណងសមាហរណកម្មហិរញ្ញវត្ថុនៅកម្ពុជាមានប្រសិទ្ធភាព និងទូលំទូលាយបន្ថែមឡើង។ ឧស្សាហកម្ម អាជីវកម្មតូច មធ្យម និងបុគ្គលទូទៅទទួលបានអត្ថប្រយោជន៍យ៉ាងច្រើនពីការប្រើប្រាស់ KHQR ក្នុងជីវភាពប្រចាំថ្ងៃ។

ក្រោយពីបានសិក្សាស្រាវជ្រាវពីធនាគារជាតិរួចមក ក្រុមយើងខ្ញុំអាចសន្និដ្ឋានបានថា ធនាគារជាតិមានការរីកចម្រើនទៅលើការប្រើប្រាស់ប្រព័ន្ធ KHQR ដោយសារ KHQR ដែលជាកូដ QR ស្តង់ដាមួយសម្រាប់ទូទាត់ប្រាក់ឌីជីថល ដែលបានបង្កើតឡើងដោយធនាគារជាតិ នៃកម្ពុជា ដើម្បីសម្រួលការទូទាត់ជំរុញការប្រើប្រាស់បច្ចេកវិទ្យា ការរួមបញ្ចូលហិរញ្ញវត្ថុ កាត់បន្ថយថ្លៃដើម និងពេលវេលា ការរួមបញ្ចូលជាមួយប្រព័ន្ធអន្តរជាតិ និងសមភាពនៃប្រព័ន្ធបង់ប្រាក់ KHQR មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការបង្កើនភាពងាយស្រួលក្នុងការបង់ប្រាក់ សន្សំសំចៃពេលវេលា កាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ លើកតម្កើងប្រាក់រៀលខ្មែរ បង្កើនសុវត្ថិភាព ភាពទុកចិត្ត និងជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថល។ ធនាគារជាតិកម្ពុជាបានបណ្តុះបណ្តាលដល់សាធារណៈជន អំពីសារៈសំខាន់នៃ KHQR ដើម្បីបង្កើនអត្រាប្រើប្រាស់ជាសកល។

# មាតិកា


ទំព័រ

អារម្ភកថា ........ i

របនាសម្ព័ន្ធ........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ vi

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

មាតិកា........ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ........ ១

១. តើប្រព័ន្ធទូទាត់ ខេអេចឃ្យូអរ (KHQR) ផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់ប្រព័ន្ធធនាគារ និងស្ថាប័នហិរញ្ញវត្ថុ?

២. តើប្រព័ន្ធទូទាត់ ខេអេចឃ្យូអរ (KHQR) ផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជាមានអ្វីខ្លះ?

១.៣ គោលបំណងនៃការស្រាវជ្រាវ........ ២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៤.១ ទំហំដែនកំណត់ ........ ២

១.៤.២ វិសាលភាពនៃការស្រាវជ្រាវ........ ២

១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ........ ២

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ........ ៣

១.៦.១ សម្រាប់អ្នកចុះកម្មសិក្សាផ្ទាល់ ........ ៣

១.៦.២ សម្រាប់និស្សិត ........ ៣

១.៦.៣ សម្រាប់សង្គម ........ ៣

១.៧ របនាសម្ព័ន្ធនៃការស្រាវជ្រាវ........ ៤

## ជំពូកទី២
## អត្ថប្រយោជន៍នៃការប្រើប្រាស់ ខេអេចឃ្យូអរ

២.១ លក្ខណៈទូទៅនៃការប្រើប្រាស់KHQR........៥

២.១.១ និយមន័យKHQR........៥

២.១.២ ប្រវត្តិនៃKHQR........៥

២.១.៣ ទ្រឹស្តីនៃKHQR ......................................................................................................៦
២.២ អត្ថប្រយោជន៍នៃការប្រើប្រាស់ ខេអេចឃ្យូអរ ..........................................................................៦
២.២.១ និយមន័យKHQR ......................................................................................................៦
២.២.២ ប្រវត្តិKHQR ..........................................................................................................៦
២.២.៣ ទ្រឹស្តីKHQR ..........................................................................................................៧
២.៣ នីតិវិធីនៃការប្រើប្រាស់ខេអេចឃ្យូអរ ដំណើរការទូទាត់ ..........................................................៧
២.៣.១ និយមន័យរបស់នីតិ ....................................................................................................៧
២.៣.២ នីតិវិធីនៃការប្រើប្រាស់ខេអេចឃ្យូអរ ..................................................................................៨
២.៣.៣ នីតិវិធីនៃដំណើរការនៃការទូទាត់ .....................................................................................៨

## ជំពូកទី៣
## សារៈសំខាន់នៃការប្រើប្រាស់ ខេអេចឃ្យូអរ ធនាគារជាតិ

៣.១ ស្ថានភាពទូទៅនៃធនាគារជាតិ ..........................................................................................៩
៣.១.១ ប្រវត្តិរបស់ធនាគារជាតិ ..................................................................................................៩
៣.១.២ បេសកកម្ម ទស្សនវិស័យ និងគោលដៅរបស់ធនាគារជាតិ ..................................................១៥
ក.បេសកកម្ម ..................................................................................................................១៥
ខ.ទស្សនវិស័យ ................................................................................................................១៥
គ.គោលដៅ ...................................................................................................................១៥
៣.១.៣ រចនាសម្ព័ន្ធរបស់ធនាគារជាតិ .........................................................................................១៦
៣.២ ប្រព័ន្ធទូទាត់ ខេអេចឃ្យូអរ (KHQR) ផ្តល់អត្ថប្រយោជន៍ដល់ប្រព័ន្ធធនាគារ និងស្ថាប័នហិរញ្ញវត្ថុ....១៨
៣.២.១ អត្ថប្រយោជន៍ ខេអេចឃ្យូអរ (KHQR) សម្រាប់ធនាគារ ....................................................១៨
៣.២.២ អត្ថប្រយោជន៍ ខេអេចឃ្យូអរ (KHQR) សម្រាប់ស្ថាប័នហិរញ្ញវត្ថុ ..........................................១៨
៣.២.៣ ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់KHQR ..................................................១៩
ក.ការផ្សព្វផ្សាយដោយផ្ទាល់ ...............................................................................................១៩
ខ.ការផ្សព្វផ្សាយដោយប្រយោល ...........................................................................................១៩
៣.៣ ប្រព័ន្ធទូទាត់ ខេអេចឃ្យូអរ (KHQR) ផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា ................................២០

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ...................................................................................................២២
៤.២ ការវិភាគលើចំណុចខ្សោយ ................................................................................................២២

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ..........................................................................................................២៣
៥.២ ការផ្តល់អនុសាសន៍ ..........................................................................................................២៣

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

យើងបានដឹងរួចមកហើយថា នៅក្នុងសកលលោកនេះមានបណ្តាប្រទេសមួយចំនួនដែលស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយនៅក្នុងប្រទេសទាំងនោះក៏មានប្រទេសកម្ពុជាផងដែរ ដែលស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ កម្ពុជាក៏ជាប្រទេសមួយដែលកំពុងតែអភិវឌ្ឍទៅលើគ្រប់វិស័យជាពិសេសប្រព័ន្ធបច្ចេកវិទ្យាទំនើប ។ ព្រះរាជាណាចក្រកម្ពុជា ក៏ជាប្រទេសមួយដែលធ្លាប់បានជួបប្រទះក៏ដូចជាបានឆ្លងកាត់នូវសង្គ្រាមឈឺចាប់ជាច្រើនសតវត្សមកហើយ ដែលជាហេតុបណ្តាលឱ្យប្រជារាស្ត្រនៅក្នុងប្រទេសទាំងមូល ជួបទុក្ខលំបាក បាត់បង់ធនធានមនុស្ស បាត់បង់សេដ្ឋកិច្ចជាតិធ្វើឱ្យគ្មានការរីកចម្រើនប្រទេសជាតិធ្លាក់ចុះជាដរាបស្ទើរតែ មិនអាចស្តារឡើងវិញបាន។ ដោយសារប្រទេសកម្ពុជាជួបនៅបញ្ហាទាំងអស់នេះទើបធ្វើឱ្យសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាទាំងមូលមានភាពខុសគ្នាពីប្រទេសដទៃទៀតដែលស្ថិតនៅក្នុង តំបន់អាស៊ីអាគ្នេយ៍ដូចគ្នា ។ ហើយម្យ៉ាងវិញទៀតដោយសារតែមានការផ្លាស់ប្តូររបបនយោបាយនៅក្នុងប្រទេសទើបធ្វើឱ្យមានការបាត់បង់ នូវឱកាសក្នុងការធ្វើកំណែទម្រង់ប្រទេសជាតិដែលមិនអាចធ្វើឱ្យមានការរីកចម្រើន ដូចប្រទេសជិតខាង។

យ៉ាងណាមិញដោយសារតែមានការយកចិត្តទុកដាក់ និងមានការជ្រោមជ្រែងយ៉ាងស្រស្រាក់ស្រស្រាំពីរាជរដ្ឋាភិបាល បានធ្វើឱ្យប្រទេសមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ដែលធ្វើឱ្យមានការរីកចម្រើនស្ទើរគ្រប់វិស័យដូចជា វិស័យអប់រំ វិស័យបច្ចេកវិទ្យា វិស័យសេដ្ឋកិច្ចហិរញ្ញវត្ថុ និងវិស័យផ្សេងៗជាច្រើនទៀត។ ទន្ទឹមនិង ការរីកចម្រើនមួយនេះ ក៏មានការចូលរួមយ៉ាងសកម្មពីវិស័យហិរញ្ញវត្ថុជាច្រើនផងដែរ ដែលជាហេតុក្នុងការ ជួយជំរុញឱ្យសេដ្ឋកិច្ចមានការរីកចម្រើនយ៉ាងឆាប់រហ័សឡើងវិញ។ ហើយនៅក្នុងចំណោមវិស័យទាំងអស់ នោះយើងក៏បានឃើញថាមានវិស័យមួយដែលដើរតួនាទីយ៉ាងសំខាន់គឺ វិស័យបច្ចេកវិទ្យា។

អាស្រ័យហេតុនេះហើយ ទើបក្រុមរបស់យើងខ្ញុំបានធ្វើការសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តី អំពី **សារៈសំខាន់នៃការប្រើប្រាស់ ខេអេចឃ្យូអរ (KHQR) ធនាគារជាតិ** លើកយកមកស្រាវជ្រាវនិងរៀបចំជារបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

សព្វថ្ងៃនេះការប្រើប្រាស់ ខេអេចឃ្យូអរ (KHQR) នៅក្នុងប្រទេសកម្ពុជាមានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ទាំងនៅក្នុងស្រុក និងក្រៅស្រុក ដែលជាមូលហេតុមួយដែលយើងអាចនិយាយបានថាកម្ពុជា ជាប្រទេសមួយដែលមានភាពលេចធ្លោទៅលើដំណើរការបច្ចេកវិទ្យា ដែលបានជួយបំពេញតម្រូវការរបស់ប្រជាជន។ តែទោះបីជាយ៉ាងណាក៏ដោយ ប្រជាជនយើងមួយផ្នែកតូចនៅតែមិនទាន់យល់នៅអំពីដំណើរការនៃការប្រើប្រាស់ ខេអេចឃ្យូអរ (KHQR) នៅឡើយទេ ។ ដើម្បីឱ្យយល់កាន់តែច្បាស់អំពីដំណើរនៃការប្រើប្រាស់ ខេអេចឃ្យូអរ (KHQR) នេះក្រុមយើងខ្ញុំបានធ្វើការស្រាវជ្រាវ និងបកស្រាយចម្ងល់អំពីសារៈសំខាន់នៃការប្រើប្រាស់ (KHQR)។ អ្វីដែលចង់ឱ្យអ្នកអានបានដឹង នឹងកាន់យល់ច្បាស់ដូចតទៅនេះ ៖

១. តើប្រព័ន្ធទូទាត់ ខេអេចឃ្យូអរ (KHQR) ផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់ប្រព័ន្ធធនាគារ និងស្ថាប័នហិរញ្ញវត្ថុ?

២. តើប្រព័ន្ធទូទាត់ ខេអេចឃ្យូអរ (KHQR) ផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជាមានអ្វីខ្លះ ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះគឺដើម្បីពង្រឹងនៃចំណេះដឹងថ្មី គំនិតច្នៃប្រឌិតឱ្យកាន់តែយល់ច្បាស់ និងចង់សិក្សាឱ្យកាន់តែស៊ីជម្រៅទៅលើការប្រើប្រាស់ (KHQR) ប្រកបដោយប្រសិទ្ធិភាព រហ័ស ងាយស្រួលមានសុវត្ថិភាព និងច្បាស់លាស់ដែលអាចជឿទុកចិត្តបានយើងត្រូវស្វែងយល់ដូចខាងក្រោម៖

- បង្ហាញពីសារៈសំខាន់នៃការប្រើប្រាស់ ខេអេចឃ្យូអរ (KHQR)
- ស្វែងយល់ពីប្រវត្តិ និងស្ថានភាពទូទៅរបស់ ខេអេចឃ្យូអរ (KHQR)
- សិក្សាពីរបៀបនៃការប្រើប្រាស់ព្រមទាំងអត្ថប្រយោជន៍របស់ ខេអេចឃ្យូអរ (KHQR) ។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ទំហំនិងដែនកំណត់នៃការស្រាវជ្រាវនេះក្រុមរបស់យើងខ្ញុំបានលើកយកនូវសារៈសំខាន់នៃការប្រើប្រាស់ ខេអេចឃ្យូអរ ក្នុងធនាគារជាតិនៃកម្ពុជាដែលមានអាសយដ្ឋានផ្លូវលេខ១០១៩ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ តែប៉ុណ្ណោះ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

វិសាលភាពនៃការស្រាវជ្រាវនេះគឺសិក្សាទៅលើដំណើរការនៃការប្រើប្រាស់ ខេអេចឃ្យូអរ (KHQR) នៅក្នុងធនាគារជាតិនៃកម្ពុជា សម្រាប់ឆ្នាំ២០២៤ - ២០២៥ ។

## ១.៥ វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវត្រូវបានប្រើតាមវិធីសាស្ត្រគុណវិស័យផ្តោតចម្បងទៅលើការវិភាគទិន្នន័យដោយយោងពីធនាគារជាតិក៏ដូចជាឯកសារបន្ទាប់បន្សំ និងឯកសារដែលបានមកពីប្រភពគេហទំព័រដូចជា PhnomPenh Post (Khmer) និង AMS Economy ដែលពាក់ព័ន្ធទៅនិងប្រធានបទ ដើម្បីយកមកវិភាគនិងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់ អំពីការអភិវឌ្ឍន៍ និងការវិវត្តន៍នៃការប្រើប្រាស់ KHQR។

**- សម្រាប់សំណួរទី១:** ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះគឺត្រូវបានប្រមូលតាមបែបគុណវិស័យតាមរយៈទិន្នន័យ និងឯកសារផ្សេងៗដែលបានមកពីការចុះកម្មសិក្សានៅធនាគារជាតិផ្ទាល់ និងគេហទំព័រ PhnomPenh Post (Khmer) និង AMS Economy ដើម្បីយកមកបកស្រាយទៅលើការប្រើប្រាស់KHQRនិងមានសារៈសំខាន់អ្វីខ្លះ ទើបអាចឱ្យសាធារណៈជនប្រើប្រាស់ QR Code មានការរីកចម្រើនខ្ពស់ជាងមុន។

**- សម្រាប់សំណួរទី២:** ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះគឺត្រូវបានប្រមូលតាមបែបគុណវិស័យតាមរយៈទិន្នន័យ និង ឯកសារផ្សេងៗដែលបានមកពីការចុះកម្មសិក្សានៅធនាគារជាតិដោយផ្ទាល់ក៏ ដូចជាគេហទំព័ររបស់ធនាគារជាតិ, FRESH NEWS, Phnom Penh Post (Khmer), Kampuchea Thmey Dai ដើម្បីយកមកបកស្រាយលើលទ្ធផល និងផលប្រយោជន៍ដែលទទួលបានមកពីការនៃការប្រើប្រាស់KHQR។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

### ១.៦.១ សម្រាប់និស្សិតចុះកម្មសិក្សាផ្ទាល់

ការចុះកម្មសិក្សាដោយផ្ទាល់នៅធនាគារជាតិ បានផ្តល់ទាំងចំណេះដឹងថ្មីក៏ដូចជាបទពិសោធន៍ល្អៗនិងការទទួលបាននូវបរិយាកាសថ្មីប្លែក ព្រមទាំងទទួលបានព័ត៌មានពិតជាក់លាក់អំពីធនាគារជាតិ ។

**១.៦.២ សម្រាប់និស្សិត**

ការស្រាវជ្រាវពិតជាមានសារៈសំខាន់ និងមានភាពចាំបាច់ណាស់ចំពោះសិស្សានុសិស្ស ឬ និស្សិតដែលឡើងមករៀននៅសាកលវិទ្យាល័យផងដែររួមមាន៖

-ការស្រាវជ្រាវជួយពង្រឹង និងពង្រីកនូវចំណេះដឹងដល់និស្សិតឱ្យមានភាពទូលំទូលាយ

-ការស្រាវជ្រាវមានសារៈសំខាន់ណាស់ចំពោះអ្នកដែលសរសេរអត្ថបទ និងអ្នកធ្វើការងារផងដែរ

-ជំរុញឱ្យមានភាពច្នៃប្រឌិតកាន់តែខ្លាំងឡើង ឱ្យដឹងថាការស្រាវជ្រាវរបស់ដៃគូរយើងត្រូវ ឬខុស

-ធ្វើអោយយើងស្ទាត់ជំនាញក្នុងការស្រាវជ្រាវកាន់តែច្បាស់ កាន់តែល្អប្រសើរឡើង

-ធ្វើឱ្យយើងដឹងថាតើការស្រាវជ្រាវវាមានផលវិបាកយ៉ាងណាខ្លះមកកាន់យើង

- ផ្តល់នូវចំណេះដឹង កាន់តែមានភាពទូលំទូលាយ

-ជាគន្លឹះសម្រាប់អ្នកសរសេរកាន់តែទទួលបាននូវបទពិសោធន៍ថ្មីៗ និងមានភាពរីកចម្រើនទាំងសមត្ថភាពនិង ចំណេះដឹង។

**១.៦.២ សម្រាប់សង្គម**

-ការស្រាវជ្រាវជួយជំរុញឱ្យមានការអភិវឌ្ឍន៍សម្រាប់សង្គមជាតិយ៉ាងឆាប់រហ័ស

-ការស្រាវជ្រាវមានភាពចាំបាច់ណាស់ក្នុងការចូលរួមចំណែក អភិវឌ្ឍ និងការស្រាវជ្រាវជា មូលដ្ឋានក្នុងការធ្វើឱ្យមានកំហុសខុសឆ្គងកាន់តែតិច

-ការសិក្សាស្រាវជ្រាវដើម្បីពង្រីកនូវចំណេះដឹងឱ្យកាន់តែទូលំទូលាយ មានភាពសម្បូរបែប ដើម្បីអភិវឌ្ឍនៅក្នុងសង្គម

-ការស្រាវជ្រាវពីចំណេះដឹងថ្មីៗជួយឱ្យសង្គមជាតិមានការអភិវឌ្ឍន៍និងរីកចម្រើនយ៉ាងខ្លាំង ព្រោះអាចរុករកនូវបញ្ហាអ្វីមួយបានច្បាស់ កែតម្រូវទាន់ពេលវេលា

-ការស្រាវជ្រាវ ជាជម្រើសអទិភាពមួយក្នុងដំណើរការអភិវឌ្ឍន៍ស្ថាប័ន និងប្រទេសជាតិយើងដើម្បីយកទៅបណ្តុះបណ្តាលធនធានមនុស្សឱ្យកាន់តែល្អប្រសើរឡើង

-ការស្រាវជ្រាវ ជាការកំណត់នូវអត្តសញ្ញាណមួយ និងជាការរីកចម្រើនរបស់សង្គម ព្រោះសង្គមដែលរីកចម្រើនឥតឈប់ឈរគឺ មិនអាចខ្វះនូវការស្រាវជ្រាវបានទេ

-កាលណាបើយើងស្រាវជ្រាវ វាជាឧបករណ៍យ៉ាងសំខាន់មួយសម្រាប់ចំណេះដឹងសម្រាប់សង្គម ហើយការសិក្សាដែលត្រឹមតែរៀនសូត្រតាមទ្រឹស្តីរបស់គេគ្មានការស្រាវជ្រាវ គ្មានការពិចារណា គ្មានការវិភាគដែលធ្វើឱ្យគំនិតរបស់យើង គ្មានអ្វីថ្មីដើម្បីឆ្ពោះទៅរកគោលដៅបានឡើយ

-ការស្រាវជ្រាវរួមចំណែកក្នុងការអភិវឌ្ឍន៍ក្នុងការបែងចែកនូវអ្វីដែលជាការពិតឬមិនពិតបានប្រកបដោយប្រសិទ្ធភាព។ ព្រោះសព្វថ្ងៃព័ត៌មានដែលផ្សព្វផ្សាយតាមបណ្តាញសង្គមនានាមិនប្រាកដថាត្រូវទាំងអស់នោះទេ បើយើងខ្វះការស្រាវជ្រាវយើងមិនអាចវែកញែកនៅអ្វីដែលជាការពិតគឺមិនពិតបានច្បាស់ឡើយ

-ជួយបង្កើនការអនុវត្តដោះស្រាយនៅបញ្ហាជាច្រើននៅក្នុងសង្គម។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

អត្ថបទសារណានេះត្រូវបានបែងចែកជាប្រាំជំពូកដូចខាងក្រោម៖

**ជំពូកទី១៖**សេចក្តីផ្តើមជំពូកនេះបានបង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ និង សារៈសំខាន់នៃការស្រាវជ្រាវ។

**ជំពូកទី២៖**រំលឹកទ្រឹស្តីជំពូកនេះបង្ហាញពីនិយមន័យ ប្រវត្តិនិងទ្រឹស្តីដែលពាក់ព័ន្ធជាមួយអត្ថប្រយោជន៍ នៃការសិក្សាអំពីសារៈសំខាន់នៃការប្រើប្រាស់ ខេអេចឃ្យូអរ (KHQR) ។

**ជំពូកទី៣៖**លទ្ធផលនៃការស្រាវជ្រាវ បានលើកឡើងអំពីអត្ថប្រយោជន៍នៃការសិក្សាទៅលើ (KHQR) ផ្តល់ផលប្រយោជន៍ជាច្រើនក្រោយពេលស្រាវជ្រាវទៅលើកម្មវិធីមួយនេះ។

**ជំពូកទី៤៖**ការវិភាគទៅលើចំណុចខ្លាំងនិងចំណុចខ្សោយ បានបង្ហាញឡើងអំពីការវិភាគទៅលើផលវិជ្ជមាន និងផលអវិជ្ជមាននៃការប្រើប្រាស់ ខេអេចឃ្យូអរ ។

**ជំពូកទី៥៖**សេចក្តីសន្និដ្ឋាននិងការផ្តល់អនុសាសន៍ បានធ្វើសន្និដ្ឋានដោយសង្ខេបទៅលើគ្រប់ចំណុចដែលបានលើកឡើង និងធ្វើការវិភាគ និងការផ្តល់យោបល់ជាអនុសាសន៍ទៅលើគ្រប់ចំណុចដែលត្រូវកែលម្អ។

# ជំពូកទី២
# អត្ថប្រយោជន៍នៃការប្រើប្រាស់ ខេអេចឃ្យូអរ

## ២.១ លក្ខណៈទូទៅនៃការប្រើប្រាស់KHQR

### ២.១.១ និយមន័យKHQR

KHQR គឺជាមធ្យោបាយស្កេនបង់ប្រាក់ជាទីទុកចិត្តនិងពេញនិយមបំផុតដែលទទួលប្រាក់ទូទាត់ជាទឹកប្រាក់រៀលនឹងដុល្លារផតគិតថ្លៃសេវាពីអ្នកប្រើប្រាស់ KHQR រាប់លាននាក់។

KHQR (Cambodia QR Code)គឺជាប្រព័ន្ធការទូទាត់ប្រាក់ដោយប្រើកូដ QR ដែលត្រូវបានអភិវឌ្ឍនៅកម្ពុជា ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់កូដ QR សម្រាប់ការទូទាត់ក្នុងប្រព័ន្ធឌីជីថល ដែលមានសុវត្ថិភាព និងអនុវត្តបានសាមញ្ញ។

KHQR គឺជាកូដ QR ដែលប្រើសម្រាប់ការទូទាត់ប្រាក់តាមប្រព័ន្ធឌីជីថលនៅកម្ពុជា។ វាជាប្រព័ន្ធដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើការទូទាត់ដោយមិនត្រូវការប្រើប្រាស់ប្រាក់ដុល្លារឬ កាតបណ្ណុំនោះទេប៉ុន្តែត្រូវការស្កេនកូដ QR ពីប្រព័ន្ធនៃអ្នកលក់ហើយ ធ្វើការទូទាត់តាមក្របខ័ណ្ឌនៃកម្មវិធីទូទាត់ជាមួយក្រុមហ៊ុនធនាគារ។

QR Code គឺជាប្រភេទបាកូដដែលអាចអានបានយ៉ាងងាយស្រួលដោយប្រើប្រាស់ឧបករណ៍ឌីជីថលហើយរក្សាទុកព័ត៌មានជាស៊េរីភីកសែលក្នុងក្រឡាចត្រង្គរាងការ៉េ ត្រូវបានបង្កើតឡើងដំបូងបង្អស់ក្នុងឆ្នាំ 1994 ដោយក្រុមហ៊ុនជប៉ុន Denso Wave ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ Toyota, QR Code ក៏អាចត្រូវបានចាត់ទុកថាជាឧបករណ៍ផ្ទុកទិន្នន័យផងដែរ ដោយនៅពេលដែលអ្នកប្រើប្រាស់ស្កែនដោយប្រើកម្មវិធីអាន QR Code អ្នកនឹងទទួលបាន មាតិកាដែលមាននៅក្នុង QR Code នោះភ្លាមៗ។ មាតិកាទាំងនេះរួមមានតំណភ្ជាប់ទៅគេហទំព័រ ទៅទីតាំងភូមិសាស្ត្រ ព័ត៌មានសម្ងាត់ភ្ជាប់ Wi-Fi ឬការបង់ប្រាក់តាមសេវាកម្មធនាគារជាដើម[1]។

### ២.១.២ ប្រវត្តិ KHQR

នៅទសវត្សរ៍ ១៩៦០ លោក Masahiro Hara ទទួលបន្ទុកការអភិវឌ្ឍន៍ និងជាអ្នកដែលកំពុងបង្កើតលេខកូដ 2Dនៅប្រទេសជប៉ុនឈានដល់ដំណាក់កាល អភិវឌ្ឍសេដ្ឋកិច្ចខ្ពស់ ផ្សារទំនើបៗ លក់ទំនិញជាច្រើនតាំងពីគ្រឿងឧបបរិភោគ រហូតដល់សម្លៀកបំពាក់បានចាប់ផ្ដើមផុសផុលនៅតាមសង្កាត់ជាច្រើន ការទូទាត់ប្រាក់ដែលបន្ទាប់មក ត្រូវបានគេប្រើនឹងបញ្ចូលបង់ប្រាក់នៅក្នុងហាងទាំងនោះបានទាមទារឱ្យមានការវាយតម្លៃខ្ពស់ដោយដៃដោយសារតែបញ្ហានេះអ្នកគិតលុយជាច្រើនបានទទួលរងនូវការចុកដៃនឹងចុកខ្នង។ នៅចំពោះមុខនេះអ្នកគិតលុយត្រូវការយ៉ាងខ្លាំងនៅការប្រើវិធីមួយចំនួនដើម្បីសម្រាលបន្ទុកដល់ពួកគាត់ ហើយក្រោយមកការច្នៃប្រឌិត QR Code បានផ្ដល់នូវដំណោះស្រាយចំពោះបញ្ហានេះ។ QR Code ត្រូវបានបង្កើតឡើងដើម្បី ៖

- តាមដានគ្រឿងបន្លាស់រថយន្តក្នុងរោងចក្រ (គ្រប់គ្រងស្តុក)
- មានសមត្ថភាពផ្ទុកព័ត៌មានបានច្រើនជាង Barcode ធម្មតា

[1]ស្វែងយល់ពីនិយមន័យKHQRការិយាល័យឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ(ប្រភពថ្ងៃទី២៣ខែមិថុនាឆ្នាំ២០២៣)
https://share.google/6cuVRLCXL0AxlhUR0

• អាចស្កេនបានយ៉ាងលឿន Denso Wave មិនបានចុះបញ្ជីសិទ្ធិបញ្ញា ដាក់ពាណិជ្ជកម្មលើ QR Code នោះទេ។

• បើនិយាយឱ្យកាន់តែយល់៖ QR Code គឺជាបច្ចេកវិទ្យាដែលមានសេរីភាពក្នុងការប្រើប្រាស់ដោយគ្មានការទាមទារសិទ្ធិ។

ចាប់តាំងពីឆ្នាំ ២០០០ QR Code បានពង្រីកការប្រើប្រាស់ទៅដល់ ការផ្សព្វផ្សាយពាណិជ្ជកម្មបែបឌីជីថលការទូទាត់ (QR Payment) ការចុះឈ្មោះ Online និងបច្ចុប្បន្នក្នុងវិស័យសុខភាព COVID-19[2] ។

**២.១.៣ ទ្រឹស្តី KHQR**

KHQR គឺជាមធ្យោបាយនៃការទូទាត់ដែលអនុញ្ញាតអោយយើងធ្វើការស្កេនទូទាត់ឆ្លងបាគងទៅធនាគារផ្សេងបាន ដោយសុវត្ថិភាព ។

## ២.២ អត្ថប្រយោជន៍នៃការប្រើប្រាស់ ខេអេចឃ្យូអរ

**២.២.១ និយមន័យ KHQR**

ប្រព័ន្ធទូទាត់ KHQR របស់ធនាគារជាតិនៃកម្ពុជា គឺជាប្រព័ន្ធ ស្កេនកូដ QR ស្តង់ដារជាតិ ដែលអភិវឌ្ឍឡើងដោយធនាគារជាតិនៃកម្ពុជា (NBC) ដើម្បីអនុញ្ញាតឱ្យអតិថិជនធនាគារ និងស្ថាប័នហិរញ្ញវត្ថុធ្វើការទូទាត់ប្រាក់ឌីជីថល យ៉ាងងាយស្រួល និងមានសុវត្ថិភាព។

KHQR គឺជាកូតស្តង់ដាររួម ដែលត្រូវបានអភិវឌ្ឍដោយធនាគារជាតិនៃកម្ពុជា ហើយអាចឱ្យកម្មវិធីទូរស័ព្ទរបស់សមាជិក (បច្ចុប្បន្ន ៣៧គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ) អាចស្កេន KHQR និងធ្វើការទូទាត់ប្រាក់បាន។ កម្មវិធីទូរស័ព្ទរបស់គ្រឹះស្ថានជាសមាជិកបាគងនីមួយៗក៏មានស្តង់ដារ KHQR ដែរព្រមទាំងអាចស្កេនទូទាត់គ្នាទៅវិញទៅមកបានផងដែរ។

**+ អត្ថប្រយោជន៍:**

-ភាពងាយស្រួល៖ KHQRអាចធ្វើការទូទាត់ប្រាក់បានតាមរយៈស្មាតហ្វូននិងកម្មវិធីទូទាត់តាមស្មាតហ្វូនដែលអាចប្រើបាននៅក្រុមហ៊ុនធនាគារប្រកបដោយ KHQR។

-សុវត្ថិភាព៖ ប្រព័ន្ធមានសុវត្ថិភាពខ្ពស់ដោយបញ្ចូលការពិនិត្យ សុវត្ថិភាព និងការពារបានទិន្នន័យផ្ទាល់ខ្លួន។

-ការបង់ប្រាក់ឆាប់រហ័ស៖ អ្នកអាចបង់ប្រាក់បានក្នុងរយៈពេលខ្លី ក្រោមរយៈពេលបន្ទាន់។

**+ ការប្រើប្រាស់:**

-នៅក្នុងហាង៖ ការប្រើKHQR អ្នកអាចធ្វើការទូទាត់នៅពេលដែលអ្នកទិញទំនិញនៅក្នុងហាងដោយស្កេនកូដ QR។

-ធ្វើការទូទាត់អនឡាញ៖ KHQRអាចប្រើក្នុងការទូទាត់សេវាកម្ម ដូចជាការទូទាត់វិក្កយបត្រនិងសេវាផ្សេងៗ។

---

[2] ប្រវត្តិ QR Code លោក MASAHIRO HARA ទទួលបន្ទុកការអភិវឌ្ឍ QR Code និងជាអ្នកដែលកំពុងបង្កើតលេខកូដ 2D។ (ប្រភពថ្ងៃទី២០ ខែកុម្ភៈឆ្នាំ២០២៣ About Knowledge) Retireved from https://youtu.be/RYIHxeq6i4s?si=VfmmwwmTXxXbk_sS

-នៅក្នុងការទូទាត់ប្រតិបត្តិការការងារ៖ អ្នកអាចធ្វើការទូទាត់ក្នុងការអនុវត្តន៍ការងារ ដូចជាការបង់ប្រាក់កម្ចីឬសេវាកម្មអាជីវកម្មជាក់លាក់។

**២.២.២ ប្រវត្តិ KHQR**

នៅចន្លោះឆ្នាំ ២០១៩-២០២០ ការចាប់ផ្តើមគម្រោង

• ទីបំផុតនៃការបង្កើត KHQR គឺដោយធនាគារជាតិនៃកម្ពុជា (NBC) ដែលចង់បង្កើតប្រព័ន្ធទូទាត់ឌីជីថលមួយដែលមានស្តង់ដារជាតិ។

• NBC បានចូលរួមជាមួយស្ថាប័នហិរញ្ញវត្ថុ និងបណ្តាញនានាដើម្បីបង្កើត KHQR តាមស្តង់ដារ QR Code ដែលអាចប្រើបានជាសកល ។

ការបើកប្រើជាផ្លូវការជាសាធារណៈ (ឆ្នាំ ២០២១)

• ខែតុលា ២០២១: KHQR ត្រូវបានប្រកាសបើកប្រើជាផ្លូវការដោយធនាគារជាតិ។

• វាធ្វើឱ្យប្រព័ន្ធទូទាត់តាម QR Code ត្រូវបានសហការជាអន្តរជាតិដោយធនាគារ និងស្ថាប័នហិរញ្ញវត្ថុគាំទ្រទាំងអស់។

ការពង្រីក និងយកទៅអនុវត្តយ៉ាងទូលំទូលាយ (២០២១ - បច្ចុប្បន្ន)

• KHQR ត្រូវបានគាំទ្រដោយធនាគារ និងស្ថាប័នជាច្រើន (ABA, ACLEDA, Wing, TrueMoney, និងផ្សេងៗ)។

• អ្នកលក់តូចៗក្នុងទីផ្សារ ត្រូវបានលើកទឹកចិត្តឱ្យប្រើ KHQR ដើម្បីទទួលប្រាក់ពីអតិថិជន។

• NBCបានដំណើរការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដើម្បីលើកកម្ពស់ការយល់ដឹងអំពី "សេដ្ឋកិច្ចគ្មានសាច់ប្រាក់" និងការប្រើប្រាស់ប្រាក់ឌីជីថល។

ធនាគារជាតិនៃកម្ពុជា បានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការសេវាទូទាត់ ខេអេចឃ្យូអរ (KHQR) ដែលជាមធ្យោបាយទូទាត់ថ្មីស្របតាមស្តង់ដារអន្តរជាតិ ហើយនឹងចូលរួមចំណែកជំរុញនវានុវត្តន៍ និងបច្ចេកវិទ្យាហិរញ្ញវត្ថុលើការប្រើប្រាស់សេវាធនាគារ និងហិរញ្ញវត្ថុប្រកបដោយជំនឿទុកចិត្ត សុវត្ថិភាព ប្រសិទ្ធភាព ស្ថិរភាព និងបរិយាបន្ន [3]។

**២.២.៣ ទ្រឹស្តី KHQR**

ធនាគារជាតិនៃកម្ពុជា (NBC) បានប្រកាសដាក់ឱ្យដំណើរការប្រព័ន្ធ KHQR ដើម្បីផ្តល់ភាពងាយស្រួលដល់ការទូទាត់ឆ្លងគ្រឹះស្ថានធនាគារនិងលើកទឹកចិត្តធុរជននិងអ្នកប្រើប្រាស់ទាញប្រយោជន៍ឱ្យអស់លទ្ធភាព ពីការប្រើប្រាស់សមិទ្ធផលមួយនេះដើម្បីជំរុញនវានុវត្តន៍នៃបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យ ធនាគារ និង ហិរញ្ញវត្ថុ ។

-សម្រាប់ការទូទាត់នៅក្នុងប្រទេស ឱ្យមានសណ្តាប់ធ្នាប់ សុវត្ថិភាព

-រួមចំណែកលើកកម្ពស់អន្តរប្រតិបត្តិការនៃការទូទាត់តាម QR Code ឆ្លងគ្រឹះស្ថានសម្រាប់អតិថិជន

-ផ្តល់លទ្ធភាពសម្រាប់ប្រទេសកម្ពុជា ក្នុងការធ្វើសមាហរណកម្មការទូទាត់ក្នុងតំបន់។

[3]សេចក្តីប្រកាសព័ត៌មានស្តីពីការដាក់ដំណើរការជាផ្លូវការ ខេអេចឃ្យូអរ លេខ ធ១៤-០២២-០០៦ ដកស្រង់ចេញពីគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា (National Bank Of Cambodia) Retrired from https://www.nbc.gov.kh/

## ២.៣ នីតិវិធីនៃការប្រើប្រាស់ខេអេចឃ្យូអរ ដំណើរការនៃការទូទាត់

### ២.៣.១ និយមន័យរបស់នីតិ

នីតិជាក្បួនច្បាប់ ឬបទបញ្ញាដែលរដ្ឋ ឬអង្គភាពមានអំណាចបានកំណត់ឡើង ដើម្បីគ្រប់គ្រងសង្គមឱ្យមានសណ្ដាប់ធ្នាប់។

ក្នុងនិតិសាស្ត្រ "នីតិ" គឺជាច្បាប់ ឬក្រមច្បាប់ ដែលកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងអង្គភាព។

ក្នុងប្រើប្រាស់ប្រចាំថ្ងៃពាក្យ "នីតិ" ក៏អាចមានន័យថា ក្បួន, ច្បាប់តាមអង្គភាព, ឬវិធានការណ៍ណាមួយដែលត្រូវគោរព[4]។

### ២.៣.២ នីតិវិធីនៃការប្រើប្រាស់ខេអេចឃ្យូអរ

នីតិវិធីនៃការប្រើប្រាស់ KHQR នៅកម្ពុជា តាមការកំណត់របស់ ធនាគារជាតិនៃកម្ពុជា (NBC) និងស្ថាប័នហិរញ្ញវត្ថុ មានដំណើរការទូទៅដូចខាងក្រោម៖

- ការចុះឈ្មោះប្រើប្រាស់ ត្រូវមានគណនីជាមួយស្ថាប័នហិរញ្ញវត្ថុណាមួយដែលជាសមាជិកបណ្ដាញ KHQR ។

- ការទទួល KHQR Code បន្ទាប់ពីចុះឈ្មោះ ស្ថាប័នហិរញ្ញវត្ថុផ្ដល់ KHQR Code (ស្ដង់ដារតែមួយសម្រាប់គ្រប់ធនាគារ)។

-ការទទួលប្រាក់អាជីវករ និងអ្នកទទួលប្រាក់អាចពិនិត្យសមតុល្យប្រាក់ចូលតាម Mobile Banking Wallet។ ប្រាក់អាចដកជាសាច់ប្រាក់តាម ATM ឬប្ដូរទៅគណនីធនាគារ។

- សុវត្ថិភាពនិងបទបញ្ញា អ្នកប្រើត្រូវរក្សាកូដសម្ងាត់ និងទិន្នន័យផ្ទាល់ខ្លួនឱ្យសុវត្ថិភាពមិនគួរបង្ហាញ PIN/OTP ទៅអ្នកដទៃ បើមានករណីចម្លង QR Code ឬប្រតិបត្តិការមិនប្រក្រតី អ្នកប្រើអាចរាយការណ៍ទៅធនាគារ ឬNBC។

### ២.៣.៣ នីតិវិធីនៃដំណើរការនៃការទូទាត់

នីតិវិធីនៃដំណើរការនៃការទូទាត់គឺជាលំដាប់ជំហានត្រឹមត្រូវ ដែលអ្នកប្រើ និងស្ថាប័នហិរញ្ញវត្ថុត្រូវអនុវត្ត ដើម្បីឱ្យប្រតិបត្តិការទូទាត់មានប្រសិទ្ធភាព និងសុវត្ថិភាព។

- អតិថិជន បើកកម្មវិធី Mobile Banking, Wallet របស់ខ្លួន។
- ជ្រើសមុខងារ ស្កេន QR។
- ស្កេន KHQR Code របស់អ្នកលក់ ឬអ្នកផ្ដល់សេវា។
- បញ្ចូលចំនួនទឹកប្រាក់ (បើគ្មានសរសេរដោយស្វ័យប្រវត្តិ)។
- ពិនិត្យព័ត៌មាន (ឈ្មោះអ្នកទទួលឬចំនួនទឹកប្រាក់)។
- បញ្ជាក់ការទូទាត់ ដោយប្រើ PIN, OTP, Fingerprint, Face ID។
- អ្នកទទួលនិងអ្នកបង់ប្រាក់ទទួលបាន SMS ឬ Notification ឱ្យដឹងថាប្រតិបត្តិការបានជោគជ័យ។

[4] និយមន័យនិតី ប្រភពថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២៣ Retrieved from https://thmeythmey.com/

# ជំពូកទី៣

# សារៈសំខាន់នៃការប្រើប្រាស់ ខេអេចឃ្យូអរ ធនាគារជាតិ

## ៣.១ ស្ថានភាពទូទៅនៃធនាគារជាតិ

### ៣.១.១ ប្រវត្តិរបស់ធនាគារជាតិ

ធនាគារជាតិនៃកម្ពុជាមានប្រវត្តិយូរអង្វែង ដែលអាចបែងចែកជាបួនដំណាក់កាលដូចខាងក្រោម ៖

- ឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៦៤: ប្រទេសកម្ពុជាទទួលបានឯករាជ្យពីអាណានិគមនិយមបារាំងក្នុងឆ្នាំ ១៩៥៣ ហើយធនាគារជាតិនៃកម្ពុជាក៏ត្រូវបានបង្កើតឡើង ។ ធនាគារជាតិនៃកម្ពុជាទទួលភារៈផ្តាច់មុខជាអ្នកបោះពុម្ពប្រាក់រៀល ដែលជារូបិយវត្ថុជាតិ និងគ្រប់គ្រងប្រព័ន្ធធនាគារនៅកម្ពុជា។

- ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩: ធនាគារជាតិនៃកម្ពុជាត្រូវបានបិទដោយសារតែរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ។ អគារស្នាក់ការត្រូវបានកម្ទេច រូបិយវត្ថុជាតិត្រូវបានឈប់ប្រើប្រាស់ ហើយប្រព័ន្ធធនាគារត្រូវបានលុបបំបាត់ចោលទាំងស្រុង ។

- ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣: ធនាគារជាតិនៃកម្ពុជាត្រូវបានកសាងឡើងវិញពីចំណុចសូន្យ។ ទន្ទឹមនឹងនេះរូបិយវត្ថុជាតិក៏ត្រូវបានបោះផ្សាយឡើងវិញ។ កម្ពុជាបានប្តូរពីសេដ្ឋកិច្ចផែនការទៅជាសេដ្ឋកិច្ចទីផ្សារសេរី។

- ឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន: ប្រព័ន្ធធនាគារត្រូវបានពង្រឹង និងធ្វើទំនើបភាវូបនីយកម្មជាលំដាប់ហើយកម្ពុជាបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្លាំងជាងគេ នៅលើពិភពលោក ។



ឯករាជ្យភាព និងការបង្កើតឡើងវិញ ( ១៩៥៤-១៩៦៤ )

ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងនៅខែធ្នូ ឆ្នាំ១៩៥៤ បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យពីអានិគមនិយមបារាំង និងបន្ទាប់ពីវិទ្យាស្ថានបោះប្រាក់ឥណ្ឌូចិនត្រូវបានបិទទ្វារ។




មុនទទួលបានឯករាជ្យ វិទ្យាស្ថានបោះប្រាក់ដែលទីតាំងនៅប្រទេសកម្ពុជា បានបោះពុម្ព រូបិយវត្ថុរួមគ្នាសម្រាប់បីប្រទេសនៅឥណ្ឌូចិនគឺ ប្រទេសកម្ពុជា ប្រទេសឡាវ និងវៀតណាម។






បន្ទាប់ពីទទួលបានឯករាជ្យ ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយរូបិយវត្ថុជាតិ (ប្រាក់រៀល) ដើម្បីបំពេញអធិបតេយ្យភាពក្នុងការរក្សាស្ថិរភាពរូបិយវត្ថុ និងជួយកសាងអត្តសញ្ញាណជាតិ ។ ក្នុងពេលនោះដែរប្រព័ន្ធធនាគារក្នុងស្រុកត្រូវបានកសាងឡើងវិញដែលមានទាំងធនាគាររដ្ឋ និងឯកជនធ្វើប្រតិបត្តិការរួមគ្នា ។



ក្នុងសម័យសង្គមរាស្ត្រនិយមនាទសវត្សរ៍ឆ្នាំ១៩៦០ ក្រោមការដឹកនាំរបស់ព្រះបាទ នរោត្តមសីហនុ ព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍន៍រីកចម្រើនទូទាំងផ្ទៃប្រទេស ។ នៅឆ្នាំ១៩៦៤ ប្រព័ន្ធធនាគារត្រូវបានធ្វើកំណែទម្រង់ ដើម្បីឱ្យត្រូវតាមតម្រូវការសេដ្ឋកិច្ច និងការអភិវឌ្ឍន៍នាសម័យនោះ ដោយបានប្រែក្លាយធនាគារជាតិនៃកម្ពុជាពីទម្រង់ស្ថាប័នពាក់កណ្តាលស្វយ័ត ទៅជាធនាគាររដ្ឋក្រោមទម្រង់ជាស្ថាប័នសាធារណៈ ដែលមានលក្ខណៈ ឧស្សាហកម្ម និងពាណិជ្ជកម្ម ។ ទន្ទឹមនឹងនេះដែរ ធនាគារសាធារណៈ និងឯកជនជាច្រើន ត្រូវបានបិទ ហើយរាជរដ្ឋាភិបាលបានកសាងធនាគារដែលគ្រប់គ្រងដោយរដ្ឋមួយចំនួនដូចជាធនាគារឥណទានសម្រាប់ការអភិវឌ្ឍន៍ និងធនាគារកសិកម្មជនបទ។



របបខ្មែរក្រហម ( ១៩៧៥-១៩៧៩ )

នាថ្ងៃ១៧ ខែមេសាឆ្នាំ១៩៧៥ នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យ ( ខ្មែរក្រហម ) កាន់អំណាច ធនាគារជាតិនៃកម្ពុជាត្រូវបានបិទទ្វារ អគារស្នាក់ការត្រូវបានកម្ទេច រូបិយវត្ថុ ជាតិត្រូវបានឈប់ប្រើប្រាស់ ហើយប្រព័ន្ធធនាគារត្រូវបានលុបបំបាត់ចោលទាំងស្រុង ។ នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហម ត្រូវបានគេផ្តួលរំលំ ហើយធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ក្នុង នាមជាធនាគារកណ្តាលរបស់ប្រទេស និងត្រូវបានប្តូរឈ្មោះជា"ធនាគារជាតិនៃប្រជាជនកម្ពុជា" ដោយក្រុម ប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ។ ទោះជាយ៉ាងនេះក្តីការកសាងធនាគារ ជាតិនៃកម្ពុជានិងប្រទេសជាតិបន្ទាប់ ពីសង្គ្រាមទើបនឹងបញ្ចប់ភ្លាមនេះ គឺមានការលំបាកយ៉ាងខ្លាំង។ ជាមួយនឹងការខិតខំប្រឹងប្រែងជម្នះគ្រប់ ឧបសគ្គដើម្បីកសាងប្រព័ន្ធធនាគារជាថ្មីឡើងវិញដោយផ្តើមចេញពីចំណុចសូន្យ ឯកឧត្តម ជា ចាន់តូ ទេស រដ្ឋមន្ត្រីនិងជាអភិបាល ធនាគារជាតិនៃកម្ពុជា និងជាអ្នកផ្តួចផ្តើមម្នាក់ក្នុងចំណោមអ្នកផ្តួចផ្តើមកសាង ធនាគារជាតិនៃ កម្ពុជាដទៃទៀត ព្រមទាំងបុគ្គលិកមួយចំនួនតូច ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម បានប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការកសាងធនាគារជាតិនៃកម្ពុជាឡើងវិញ ។




របបខ្មែរក្រហមបានបន្សល់ទុកនូវបញ្ហាប្រឈមជាច្រើន ។ ដោយសារបញ្ញវ័ន្តជាច្រើន រូបត្រូវបាន សម្លាប់ដោយពួកខ្មែរក្រហម និងខ្លះទៀតបានភៀសខ្លួនចេញពីប្រទេស បន្ទាប់ពីសង្គ្រាម ចំនួនអ្នកចេះដឹង អ្នកជំនាញ និងអ្នកមានបទពិសោធន៍មានចំនួនតិចតួច ។ អ្នកនៅរស់រានមានជីវិតនិងមានសមត្ថភាពមួយ ចំនួន ដែលនៅសេសសល់ក្នុងប្រទេសមានការភ័យខ្លាចក្នុងការធ្វើការ ដោយសារពួកគេមានគិតថារបបខ្មែរ ក្រហមអាចនឹងវិលត្រឡប់មកវិញ។ លើសពីនេះទៀត គឺមានកង្វះយ៉ាងធ្ងន់ធ្ងរនៃធនធានហិរញ្ញវត្ថុ ។

ក្នុងពេលដែលសេដ្ឋកិច្ចនៅទន់ខ្សោយនៅឡើយ ហើយការផ្គត់ផ្គង់សាច់ប្រាក់ស្ទើរតែ មិនមានសោះ ដោយសារតែគោលនយោបាយរបស់ខ្មែរក្រហម សកម្មភាពសេដ្ឋកិច្ចនៅតែត្រូវ បានធ្វើឡើងជាលក្ខណៈដោះ ដូរទំនិញនិងទំនិញចំណែកប្រាក់ខែមន្ត្រីរាជការស៊ីវិលត្រូវបានទូទាត់ដោយប្រើអង្ករ ត្រី ប្រេង ជាដើម ។ រហូត

ដល់ថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៨០ ធនាគារ នៃប្រជាជនកម្ពុជាបានបោះផ្សាយប្រាក់រៀលឡើងវិញ ដើម្បីសម្រួលដល់ការដោះដូរទំនិញ និងការទូទាត់ប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល ។ បើទោះបីជាជួបប្រទះបញ្ហាប្រឈមទាំងនេះ ជារៀងរាល់ថ្ងៃខែឆ្នាំក៏ដោយ ក៏មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជានៅតែបន្តពុះពារឆ្ពោះទៅមុខជានិច្ច ក្នុងការកសាងធនាគារជាតិឡើងវិញបន្តិចម្តងៗ។






ការកសាងធនាគារជាតិនៃកម្ពុជាឡើងវិញ (១៩៧៩-១៩៩៣)

ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ធនាគារនៃប្រជាជនកម្ពុជាមានតួនាទីចម្បងៗបីគឺ ជា អាជ្ញាធររូបិយវត្ថុ ជារតនាគារជាតិ និងជាអ្នកផ្តល់សេវាកម្មធនាគារ ដែលរួមមាន សេវា ឥណទាន សេវាទទួលប្រាក់បញ្ញើ និងសេវាទូទាត់ ។ ចាប់តាំងពីអគារស្នាក់ការធនាគារជាតិ នៃកម្ពុជាត្រូវបានកម្ទេចទៅដោយខ្មែរក្រហម ស្នាក់ការកណ្តាលបណ្តោះអាសន្នរបស់ធនាគារ ត្រូវបានបើកនៅជាន់លើនៃធនាគារខ្មែរពាណិជ្ជ ។ ធនាគារប្រជាជននៃកម្ពុជាបានបង្កើតរចនាសម្ព័ន្ធដឹកនាំដូចជា សកម្មភាពប្រតិបត្តិការជាច្រើនទៀត និងបានពង្រីកបណ្តាញសាខារបស់ខ្លួនដល់ ២៤ ខេត្ត-ក្រុងទូទាំងប្រទេស ។ ចាប់តាំងពីឆ្នាំ១៩៨៩ មក ប្រព័ន្ធធនាគារ បានធ្វើកំណែទម្រង់បន្តិចម្តងៗ តាមរយៈការផ្លាស់ប្តូរធនាគារខេត្ត-ក្រុងចំនួន២០ទៅជា ធនាគារឯកទេសខេត្ត-ក្រុង ហើយធ្វើប្រតិបត្តិការជាមួយនឹងស្វ័យភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ច នៅក្នុងដែនដីរបស់ពួកគេ។ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារនៃប្រជាជនកម្ពុជាបានត្រួតពិនិត្យលើដំណើរការរបស់ធនាគារពាណិជ្ជទាំងនោះ។ អគារស្នាក់ការធនាគារជាតិនៃ កម្ពុជាត្រូវបានកសាងឡើងវិញនៅឆ្នាំ ១៩៩០ ។



នៅឆ្នាំ១៩៩១ ធនាគារពាណិជ្ជដំបូងគេ (ធនាគារពាណិជ្ជកម្ពុជា“CCB”) ត្រូវបានបង្កើត ឡើងក្រោមទម្រង់ជាធនាគារវិនិយោគរួមគ្នារបស់រដ្ឋ ដើម្បីទាក់ទាញវិនិយោគិន និងបម្រើឱ្យសកម្មភាពអាជ្ញាធរអ៊ុនតាក់ប្រចាំនៅកម្ពុជា ។ សន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ តុលាឆ្នាំ១៩៩១ បានផ្លាស់ប្តូររបបសេដ្ឋកិច្ចកម្ពុជាពីសេដ្ឋកិច្ចផែនការមកជាសេដ្ឋកិច្ចទីផ្សារសេរី ។

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩២ រដ្ឋសភាជាតិបានអនុម័តច្បាប់ស្តីពីការប្តូរឈ្មោះ និងកាតព្វកិច្ចរបស់ធនាគារជាតិនៃកម្ពុជាពី "ធនាគារនៃប្រជាជនកម្ពុជា" មកជា "ធនាគារ ជាតិនៃកម្ពុជា" វិញ ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រុមប្រឹក្សារដ្ឋនាថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩២។ ធនាគារជាតិនៃកម្ពុជា បានចងក្រងនិងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យ ហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ ។ ឯកសារនេះ មានមុខងារជាមូលដ្ឋានគ្រឹះសម្រាប់យុទ្ធសាស្ត្រ អភិវឌ្ឍវិស័យហិរញ្ញវត្ថុង ដើម្បីបង្កើនទំនុកចិត្តរបស់សាធារណជនចំពោះប្រព័ន្ធធនាគារ និងវិធីសាស្ត្រដែលកម្ពុជាអាចធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសកល ។ ក្នុងនាមជាធនាគារកណ្តាលរបស់ជាតិ ធនាគារជាតិនៃកម្ពុជាធ្វើការកែលម្អអគារស្នាក់ការ នៅឆ្នាំ២០០៣ ដើម្បីលើកមុខមាត់ និងកិត្យានុភាពរបស់ខ្លួន ។

ប្រព័ន្ធធនាគារនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សំគាល់ ចាប់តាំងពីពាក់កណ្តាល ទសវត្សរ៍ឆ្នាំ១៩៩០ នៅពេលដែលច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងច្បាប់និងបទប្បញ្ញត្តិនានា ក៏ដូចជាគន្លឹះនៃការធ្វើកំណែទម្រង់វិស័យធនាគារសំខាន់ផ្សេងទៀតត្រូវបានអនុវត្ត ។




ទំនើបភាវូនីយកម្មប្រព័ន្ធធនាគារ (១៩៩៣-បច្ចុប្បន្ន)

ប្រព័ន្ធធនាគារនៅកម្ពុជា រួមមាន ធនាគារពាណិជ្ជចំនួន៣៦ ធនាគារឯកទេស ចំនួន១១ តំណាងធនាគារបរទេសចំនួន៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៣៩ (ក្នុងនោះរួម បញ្ចូលទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៧) ប្រតិបត្តិករឥណទានជនបទ ចំនួន៣៨ ក្រុមហ៊ុនជួលចំនួន៦ ការិយាល័យឥណទានចំនួន១, ដំណើរការតតីយភាគី ចំនួន៦ និងអាជីវករប្តូរប្រាក់ចំនួន១.៧៧០ ។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបាននិងកំពុងបន្តពង្រីក បណ្តាញប្រតិបត្តិការរបស់ខ្លួន តាមរយៈការបើកសាខា និងការិយាល័យតំណាងជាច្រើនកន្លែងក្នុងរាជធានី-ខេត្ត និងតម្លើងម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ (អេធីអឹម) បន្ថែមលើការ ផ្តល់សេវាទូទាត់អេឡិចត្រូនិក ។



ប្រព័ន្ធធនាគារនៅកម្ពុជាមានដំណើរយ៉ាងវែងឆ្ងាយ ពោលគឺចាប់តាំងពីការកសាង មូលដ្ឋានគ្រឹះប្រព័ន្ធធនាគារបន្ទាប់ពីបានទទួលឯករាជ្យ មកការបំផ្លិចបំផ្លាញនៃប្រព័ន្ធរូបិយវត្ថុ ក្នុងរបបខ្មែរក្រហម បន្ទាប់មកការទូទាត់ប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិលដោយអង្ករនិងត្រី រហូតដល់ការកសាងវិស័យធនាគារនិងហិរញ្ញវត្ថុដែលប្រកបដោយការគ្រប់គ្រងយ៉ាងល្អ និង ចាក់ស្រេះ ចាប់តាំងពីបាតដៃទទេ ។

**៣.១.២ បេសកកម្ម ទស្សនវិស័យ និងគោលដៅ របស់ធនាគារជាតិ**

បេសកកម្ម (Mission) ទស្សនវិស័យ (Vision) និងគោលដៅ (Goals) របស់ធនាគារជាតិ (National Bank) គឺជាព័ត៌មានសំខាន់ដែលកំណត់ទិសដៅ និងការសម្រេចតម្រូវការអាជីវកម្មរបស់ធនាគារនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។



**ក. បេសកកម្ម** (Mission):បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជាគឺការកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថេរភាពថ្លៃ សំដៅរួមចំណែក ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិយ៉ាងប្រសើរឡើង។

**ខ. ទស្សនវិស័យ** (Vision):ធនាគារជាតិក្លាយទៅជាធនាគារដែលមានភាពទំនើប និងប្រសើរជាងគេក្នុងការរក្សាស្ថានភាពហិរញ្ញវត្ថុជាតិនៅក្នុងប្រទេស និងទិញបញ្ចុះបញ្ជីនៅលើទីផ្សារអន្តរជាតិនៅថ្ងៃមុខ។

**គ. គោលដៅ** (Goals):

- បង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យប្រាក់ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្រទេស។
- ផ្តល់ការគាំទ្រដល់អាជីវកម្មនិងប្រជាជនក្នុងការទទួលបានសេវាកម្មហិរញ្ញវត្ថុដែលសាកសម។
- បង្កើតប្រព័ន្ធហិរញ្ញវត្ថុដែលមានសុវត្ថិភាព និងអាចគ្រប់គ្រងការប្រាក់ ប្រកបទៅដោយការយកចិត្តទុកដាក់ស្តីពីធនាគារ។

### ៣.១.៣ រចនាសម្ព័ន្ធរបស់ធនាគារជាតិ

ក្រុមប្រឹក្សាភិបាលជាគណៈគ្រប់គ្រង ដែលមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចលើផែនការ និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា នៅធនាគារជាតិនៃកម្ពុជា និងមានសមាសភាពចំនួន ៧ រូបគឺ ទេសាភិបាល ទេសាភិបាលរង តំណាងប្រមុខរដ្ឋាភិបាល តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងមជ្ឈដ្ឋានឧត្តមសិក្សា តំណាង មជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច និងតំណាង មន្ត្រី-បុគ្គលិកធនាគារធនាគារជាតិនៃកម្ពុជា។ ទេសាភិបាលជាប្រធានក្រុមប្រឹក្សាភិបាល និងមានតួនាទីជានាយកប្រតិបត្តិនៃធនាគារជាតិនៃកម្ពុជា ជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងទទួលខុសត្រូវចំពោះកិច្ចការអនុវត្តគោលនយោបាយ និងប្រតិបត្តិការប្រចាំថ្ងៃ។ ទេសាភិបាលត្រូវបានតែងតាំងដាក់ជំនួស និងបញ្ឈប់ពីតំណែងដោយព្រះរាជក្រឹត្យ ដែលយោងតាមសំណើរបស់រាជរដ្ឋាភិបាល។

ក្នុងកម្រិតបច្ចេកទេស ធនាគារជាតិនៃកម្ពុជាមាន ៩ អគ្គនាយកដ្ឋាន/អង្គភាព គឺអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកដ្ឋានប្រតិបត្តិការ អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន អគ្គបេឡា អគ្គនាយកដ្ឋានគ្រប់គ្រងសាច់ប្រាក់ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលក្នុងនោះរួមមាន ៣៨ នាយកដ្ឋាន/អង្គភាព និង១៩ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ដឹកនាំដោយប្រធាននាយកដ្ឋាន ប្រធានអង្គភាព និងនាយកសាខា។ អគ្គនាយកដ្ឋាននីមួយៗ មានតួនាទីទទួលខុសត្រូវចំពោះការអនុវត្តមុខងារប្រចាំថ្ងៃនៃប្រតិបត្តិការធនាគារកណ្តាល និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា។


NATIONAL BANK OF CAMBODIA
Riel. Stability. Development.

## ៣.២ ប្រព័ន្ធទូទាត់ ខេអេចឃ្យូអរ (KHQR) ផ្តល់អត្ថប្រយោជន៍ដល់ប្រព័ន្ធធនាគារ និង ស្ថាប័នហិរញ្ញវត្ថុ

### ៣.២.១ អត្ថប្រយោជន៍ ខេអេចឃ្យូអរ (KHQR) សម្រាប់ប្រព័ន្ធធនាគារ

- បង្កើនប្រសិទ្ធភាពសេវាកម្មទូទាត់
  - KHQR ជួយឱ្យធនាគារអភិវឌ្ឍសេវាទូទាត់ឌីជីថលងាយស្រួលកាត់បន្ថយពេលវេលា និងកាត់បន្ថយកំហុស។
  - អាចអនុវត្តបានទូទាំងប្រទេសបង្កើនភាពរហ័សនៃប្រតិបត្តិការ។
- បន្ថយថ្លៃដើមប្រតិបត្តិការ
  - ដោយសារជាស្តង់ដាររួម KHQR បន្ថយតម្រូវការបង្កើតប្រព័ន្ធខ្លួនឯង សម្រាប់ធនាគារ។
  - កាត់បន្ថយការពឹងផ្អែកលើបច្ចេកវិទ្យាផ្ទាល់ខ្លួន ។
- ជំរុញការចូលរួមរបស់អតិថិជនថ្មី
  - KHQR ជួយធនាគារទាក់ទាញអតិថិជនថ្មីៗ ដូចជាអាជីវករតូចៗនិងប្រជាជននៅតាមជនបទ។
  - ជួយដល់ការពង្រឹងនីតិវិធី Know Your Customer (KYC) ដោយបញ្ជាក់ប្រតិបត្តិការទូទៅ។
  - បង្កើតឱកាសអភិវឌ្ឍផលិតផលសេវាថ្មីៗអាចភ្ជាប់ជាមួយ Mobile Banking, e-wallet និងបច្ចេកវិទ្យាទូទាត់ផ្សេងៗដើម្បីផ្តល់បទពិសោធន៍ល្អជាងមុនដល់អតិថិជន។
  - បើកចំហសេវាកម្មដូចជា QR loan repayment, Bill payments via QR ជាដើម។
- បង្កើនភាពប្រកួតប្រជែង និងការចាប់អារម្មណ៍របស់ទីផ្សារ
  - KHQR ជួយធនាគារប្រកួតប្រជែងបានក្នុងវិស័យឌីជីថល ដោយផ្តល់សេវាទាន់សម័យ។
  - ផ្តល់ភាពទំនើប ភាពជឿជាក់ដល់អតិថិជន និងដៃគូអាជីវកម្ម។
- ជួយក្នុងការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុជាតិ
  - ព័ត៌មានលម្អិតពីប្រតិបត្តិការតាម KHQR អាចជួយធនាគារវិភាគទិន្នន័យហិរញ្ញវត្ថុ ដើម្បីផ្តល់សេវាបន្ថែម ឬបង្កើតផែនការអភិវឌ្ឍអាជីវកម្ម។

### ៣.២.២ អត្ថប្រយោជន៍ ខេអេចឃ្យូអរ (KHQR) សម្រាប់ស្ថាប័នហិរញ្ញវត្ថុ

ប្រព័ន្ធទូទាត់ KHQR ផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនសម្រាប់ប្រព័ន្ធស្ថាប័នហិរញ្ញវត្ថុនៅកម្ពុជា។ អត្ថប្រយោជន៍សំខាន់រួមមាន៖

- បន្ថែមការចូលរួមរបស់អតិថិជន (Customer Inclusion)
  - អនុញ្ញាតឱ្យអតិថិជននៅតំបន់ជនបទអាចបង់ប្រាក់កម្ចី ឬទទួលប្រាក់កម្ចីតាម QR Code
  - ជំរុញការចូលរួមក្នុងប្រព័ន្ធហិរញ្ញវត្ថុផ្លូវការ (Financial Inclusion)
- កាត់បន្ថយការចំណាយប្រតិបត្តិការ
  - មិនចាំបាច់ប្រើប្រាស់សាច់ប្រាក់ ឬចំណាយលើការជួលសាខា
  - បន្ថយការប្រើប្រាស់បុគ្គលិកសម្រាប់ប្រមូលប្រាក់
- បង្កើនប្រសិទ្ធភាពក្នុងការប្រមូលប្រាក់

- អតិថិជនអាចបង់ប្រាក់កម្ចីតាម KHQR យ៉ាងឆាប់រហ័ស
- ការប្រមូលប្រាក់មានកំណត់ត្រាថេរនិងគ្មានបញ្ហាជាមួយប្រាក់ក្លែងក្លាយ

• បង្កើនសុវត្ថិភាពនៃប្រតិបត្តិការ

- កាត់បន្ថយហានិភ័យនៃការប្រើប្រាស់សាច់ប្រាក់ក្នុងដៃ បាត់បង់ ឬបាត់ប្រាក់
- មានកំណត់ត្រាជាស្វ័យប្រវត្តិ ដែលងាយស្រួលត្រួតពិនិត្យ

• ផ្តល់បទពិសោធន៍ថ្មីដល់អតិថិជន

- អតិថិជនមានជម្រើសទូទាត់ទំនើប ងាយស្រួលប្រើត្រឹមតែទូរស័ព្ទដៃ
- បង្កើនការទំនាក់ទំនង និងភាពជិតស្និទ្ធរបស់អតិថិជនជាមួយស្ថាប័ន

• បង្កើនភាពប្រកួតប្រជែងជាមួយធនាគារ

- ស្ថាប័នហិរញ្ញវត្ថុអាចផ្តល់សេវាទូទាត់ឌីជីថលដូចធនាគារដែរ
- ទាក់ទាញអតិថិជនថ្មីៗ និងសេវាថ្មីៗ

• ជំរុញការផ្លាស់ប្តូរទៅប្រព័ន្ធឌីជីថល

- ជាជំហានសំខាន់ក្នុងការដើរពីប្រព័ន្ធប្រពៃណីទៅជាប្រព័ន្ធឌីជីថល
- ជួយអភិវឌ្ឍស្ថាប័នឱ្យទាន់បច្ចេកវិទ្យា

**៣.២.៣ ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ KHQR**

**ក.ការផ្សព្វផ្សាយដោយផ្ទាល់**

ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ KHQR ដោយផ្ទាល់របស់ធនាគារជាតិសំដៅទៅលើការផ្តល់ជូននូវប្រព័ន្ធប្រើប្រាស់បច្ចេកវិទ្យាថ្មីសម្រាប់ប្រកបអាជីវកម្ម និងការបង់ប្រាក់ដល់អតិថិជនដោយសម្រួល KHQR គឺជាកូដ QR ដែលត្រូវបានប្រើសម្រាប់ការទូទាត់ក្នុងប្រទេស ហើយបានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងប្រទេសជាច្រើនទៀត។ សារៈសំខាន់នៃការប្រើប្រាស់ KHQR គឺជាការផ្តល់នូវប្រព័ន្ធទូទាត់ដែលមានសុវត្ថិភាព និងមានភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់និងអតិថិជន។ យ៉ាងជាក់លាក់វាអាចជួយបន្ថយការប្រើប្រាស់សាច់ប្រាក់ និងលើកទឹកចិត្តការប្រើប្រាស់ប្រព័ន្ធឌីជីថលដើម្បីធានានូវភាពងាយស្រួល និងមានប្រសិទ្ធភាពក្នុងការទូទាត់ប្រាក់។

ការប្រើប្រាស់ KHQR ដោយធនាគារជាតិនៅក្នុងប្រទេសកម្ពុជាអាចជួយសម្រួលការទូទាត់ប្រាក់មុខម៉ាស៊ីនធនាគារ និងអតិថិជនសម្រាប់ផលិតផល ឬសេវាកម្មដែលពួកគេបានទិញ។ វាក៏អាចជួយសម្រេចនូវការពង្រឹងគណនេយ្យធនាគារបានយ៉ាងមានប្រសិទ្ធភាពហើយគាំទ្រដល់ការបង្កើនប្រព័ន្ធបង់ប្រាក់ឌីជីថល។ បន្ថែមលើនេះវាក៏អាចជួយដល់ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ដោយការពង្រឹងប្រព័ន្ធសេដ្ឋកិច្ចឌីជីថល ដែលអាចចូលរួមក្នុងការកែលម្អអាជីវកម្មនិងធ្វើឱ្យ មានការរីកចម្រើនលើបរិមាណទូទាត់ដែលមានប្រសិទ្ធភាព។

**ខ ការផ្សព្វផ្សាយដោយប្រយោល**

ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ KHQR (Cambodia QR Code Standard) ដោយប្រយោលរបស់ធនាគារជាតិ គឺជាការផ្តល់ឱ្យប្រជាជននឹងអាជីវកម្មអាចធ្វើការបង់ប្រាក់ និងទទួលប្រាក់ដោយ

ប្រើ QR Code ដែលគាំទ្រដោយប្រព័ន្ធ KHQR ដែលត្រូវបានកំណត់ដោយធនាគារជាតិ កម្ពុជាតាមលក្ខណៈសាកល និងសុវត្ថិភាព។

សារៈសំខាន់នៃការប្រើប្រាស់ KHQR មានអត្ថប្រយោជន៍ដូចខាងក្រោម៖

- សុវត្ថិភាពខ្ពស់: KHQR ផ្តល់នូវសុវត្ថិភាពក្នុងការបង់ប្រាក់ដោយប្រើ QR Code ដែលត្រូវបានគ្រប់គ្រងដោយធនាគារជាតិ និងប្រព័ន្ធធនាគារពេញនិយមក្នុងប្រទេស។

- ភាពងាយស្រួល: បច្ចេកវិទ្យា KHQR អនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចធ្វើការបង់ប្រាក់ឬទទួលប្រាក់ពីកន្លែងណាមួយបានដោយមិនចាំបាច់ប្រើប្រាស់កាតបង់ប្រាក់។

- ការផ្តល់ជូនសេវាកម្មគ្រប់គ្រងការបង់ប្រាក់: KHQR អនុញ្ញាតឱ្យធនាគារប្រេកបនូវសេវាកម្មបង់ប្រាក់ដោយការប្រើប្រាស់ QR Code ជាមួយគ្នាជាពិសេសនៅលើផ្ទៃទីផ្សារដូចជាខ្លួនឯង និងក្នុងអាជីវកម្មជួញដូរ។

## ៣.៣ ប្រព័ន្ធទូទាត់ ខេអេចឃ្យូអរ (KHQR) ផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា

ប្រព័ន្ធទូទាត់ KHQR (Cambodia's QR Code Payment System) ជាប្រព័ន្ធទូទាត់តាមរយៈលេខកូដ QR ដែលបានអភិវឌ្ឍដោយធនាគារជាតិនៃកម្ពុជា។ ប្រព័ន្ធនេះផ្តល់អត្ថប្រយោជន៍ចម្បងៗដូចខាងក្រោមសម្រាប់សេដ្ឋកិច្ចកម្ពុជា៖

- ជួយឱ្យមានការចូលរួមក្នុងប្រព័ន្ធហិរញ្ញវត្ថុ (Financial Inclusion) KHQR អនុញ្ញាតឱ្យអាជីវករខ្នាតតូចៗ (Micro, Small and Medium Enterprises - MSMEs) និងប្រជាជនដែលមិនមានគណនីធនាគារ ឬមិនចូលរួមក្នុងប្រព័ន្ធហិរញ្ញវត្ថុ អាចទទួលប្រាក់ឬបង់ប្រាក់បានយ៉ាងងាយស្រួលតាមទូរស័ព្ទដៃវាជួយកាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ និងលើកកម្ពស់ការចូលរួមក្នុងប្រព័ន្ធសេដ្ឋកិច្ចផ្លូវការ។
- បង្កើនប្រសិទ្ធភាពនៃប្រព័ន្ធទូទាត់ KHQR ជួយឱ្យការទូទាត់ប្រាក់កាន់តែលឿនមានសុវត្ថិភាពនិងមានតម្លាភាព (Transparency) ។
- ការអភិវឌ្ឍន៍ឌីជីថល (Digital Economy) KHQR ជួយលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដែលជាប្រេកពសំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសរុបនៅថ្ងៃអនាគត។
- បង្កើនសមត្ថភាពប្រកួតប្រជែងរបស់សហគ្រាសខ្មែរដោយសារប្រព័ន្ធ KHQR មានស្តង់ដារឯកតាសហគ្រាសអាចទទួលប្រាក់ពីអតិថិជន ដោយមិនចាំបាច់មានគណនីជាមួយធនាគារមួយណាជាក់លាក់វាក៏ជួយកាត់បន្ថយថ្លៃដើមនៃប្រព័ន្ធទូទាត់។
- លើកកម្ពស់ការរួមបញ្ចូលគ្នានៃប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ KHQR ក៏អាចត្រូវបានប្រើជាមួយប្រព័ន្ធទូទាត់ក្នុងតំបន់អាស៊ានផ្សេងៗដែលជួយសម្រួលពាណិជ្ជកម្ម និងទូទាត់អន្តរជាតិ។
- ការរីកចម្រើននៃប្រព័ន្ធសេដ្ឋកិច្ចឌីជីថល ការប្រើប្រាស់ KHQR នឹងជួយជំរុញការរីកចម្រើននៃសេដ្ឋកិច្ចឌីជីថល និងការប្រើប្រាស់ឧបករណ៍សាកលសម្រាប់បង់ប្រាក់ ដែលសមស្របសម្រាប់ការកសាងសេដ្ឋកិច្ចប្រកបដោយបច្ចេកវិទ្យា។

- កាត់បន្ថយការចំណាយ និងកើនប្រសិទ្ធភាពសេដ្ឋកិច្ច (Cost Reduction & Efficiency) ព្រមទាំងជួយឱ្យរដ្ឋមានទិន្នន័យច្បាស់លាស់សម្រាប់គ្រប់គ្រងសេដ្ឋកិច្ច និងពន្ធដារ។
- ជួយអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងបច្ចេកវិទ្យា បង្កើតបរិយាកាសថ្មីសម្រាប់ការច្នៃប្រឌិតនិងការបង្កើតសេវាថ្មីៗក្នុងវិស័យហិរញ្ញវត្ថុ។
- អភិវឌ្ឍលទ្ធផលនៃសេដ្ឋកិច្ចជាតិ ការចំណាយ និងទិញលក់កើនឡើងដោយសារភាពងាយស្រួលនៃការទូទាត់។
- បង្កើនផលិតភាព (Productivity) និងការផ្ទេរប្រាក់ក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ឆ្លងតាមការសិក្សាស្រាវជ្រាវទៅលើ សារៈសំខាន់នៃការប្រើប្រាស់ KHQR យើងខ្ញុំបានពិនិត្យឃើញថា ប្រតិបត្តិការ KHQR តែងតែមាននូវចំណុចខ្លាំងនិងចំណុចខ្សោយ ប៉ុន្តែការវិភាគនូវចំណុចទាំងនេះវាពិតជាមានសារៈសំខាន់ណាស់ពីព្រោះបានផ្តល់ភាពងាយស្រួលក្នុងការវាយតម្លៃ វាស់វែងពីដំណើរការនិងពីសកម្មភាពនៃការប្រើប្រាស់ KHQR ដើម្បីមានការអភិវឌ្ឍន៍រីកចម្រើនទៅមុខ។ ដូចនេះ ហើយសម្រាប់ការសិក្សាស្រាវជ្រាវអំពីសារៈសំខាន់នៃការប្រើប្រាស់ KHQR ឃើញថាមានភាពខ្លាំងច្រើនជាងភាពខ្សោយដែលពុំទាន់បានបំពេញបន្ថែមទៀត ។

## ៤.១ ការវិភាគលើចំណុចខ្លាំង

- បង្កើនគំនិតច្នៃប្រឌិតឱ្យកាន់តែយល់ច្បាស់ ទៅលើការប្រើប្រាស់ KHQR
- ងាយស្រួលសម្រាប់អ្នកលក់និងអ្នកទិញគ្រាន់តែស្កេនQR Codeអាចទូទាត់បង់ប្រាក់បានភ្លាមៗ
- មានភាពងាយស្រួយក្នុងការតាមដានប្រតិបត្តិការចំណូល និងចំណាយប្រកបដោយប្រព័ន្ធសុវត្ថិភាពឌីជីថល
- សុវត្ថិភាពខ្ពស់និងមានភាពងាយស្រួលនៃការប្រើប្រាស់ KHQR
- ការទូទាត់តាមមធ្យោបាយនេះ ប្រជាជនកម្ពុជាធ្វើឱ្យប្រជាជនងាកមកប្រើប្រាស់ ការទូទាត់តាមប្រព័ន្ធឌីជីថលជំនួសឱ្យសាច់ប្រាក់
- ការទូទាត់តាម QR Code ជាមធ្យោបាយទូទាត់ថ្មីមួយដែលទើបតែលេចឡើងនៅលើទីផ្សារប៉ុន្តែសេវានេះបានកើនឡើងយ៉ាងឆាប់រហ័ស និងទទួលបានការពេញនិយមគួរឱ្យកត់សម្គាល់
- រួមចំណែកលើកកម្ពស់អន្តរប្រតិបត្តិការនៃការទូទាត់តាមរយៈ QR Code ឆ្លងគ្រឹះស្ថានសម្រាប់អតិថិជន
- ជាគន្លឹះសម្រាប់និស្សិតនិងសង្គមឱ្យកាន់តែទទួលបាននូវបទពិសោធន៍ថ្មីៗ និងមានការអភិវឌ្ឍន៍
- យល់ដឹងអំពីស្ថានភាពទូទៅ និងការបង្កើតឡើងដំបូងរបស់ប្រព័ន្ធទូទាត់ខេអេចឃ្យូអរ
- យល់ដឹងកាន់តែច្បាស់អំពីរបៀបប្រើប្រាស់។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទោះបីជានៅក្នុង ការសិក្សាស្រាវជ្រាវទៅលើ សារៈសំខាន់នៃការប្រើប្រាស់ KHQR មានចំណុចខ្លាំងច្រើនពិតមែន ប៉ុន្តែរាល់ការប្រើប្រាស់នៅតែមាននូវចំណុចខ្វះខាត ឬចំណុចខ្សោយមួយចំនួនតូចដូចជា៖

- ប្រជាជន មួយផ្នែកតូចនៅតែមិនយល់ច្បាស់អំពីដំណើរការនៃការប្រើប្រាស់ KHQR នៅឡើយ
- ប្រព័ន្ធបច្ចេកវិទ្យាពុំទាន់ទូលំទូលាយ សម្រាប់ប្រជាជនមួយចំនួន
- ប្រជាជនជាច្រើននៅតំបន់ជនបទ មិនទាន់មានការយល់ដឹងច្បាស់អំពីវិធីប្រើប្រាស់
- តំបន់ខ្លះពុំមានសេវា ធ្វើឱ្យមានភាពរអាក់រអួល។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមរយៈការស្រាវជ្រាវកន្លងមកនេះដែលរួមមានការចុះកម្មសិក្សា ការស្រាវជ្រាវឯកសារ ការប្រមូលព័ត៌មាន និងការបង្កើតគម្រោងសំណួរដើម្បីប្រមូលទិន្នន័យមកបកស្រាយ លទ្ធផលនៃការស្រាវជ្រាវព្រមទាំងការស្វែងយល់អំពី ចំណុចខ្លាំងនិងចំណុចខ្សោយក្នុងប្រធានបទខាងលើមកដែលបានស្តីពី សារៈសំខាន់នៃការប្រើប្រាស់ខេអេចឃ្យូអរ ក្រុមរបស់យើងខ្ញុំអាចសន្និដ្ឋានបានថាការប្រើប្រាស់ខេអេចឃ្យូអរ មានលក្ខណៈងាយស្រួលនិងមានប្រសិទ្ធភាព កាត់បន្ថយចំណាយប្រតិបត្តិការ លើកកម្ពស់ការទូទាត់តាមឃ្យូអរកូដ(QR Code) ឆ្លងគ្រឹះស្ថាន និងជំរុញបរិយាបន្នហិរញ្ញវត្ថុ ព្រមទាំងផ្តល់លទ្ធភាពសម្រាប់ប្រទេសកម្ពុជាក្នុងការធ្វើសមាហរណកម្មការទូទាត់ក្នុងតំបន់។

ខេអេចឃ្យូអរ គឺជាសេវាកម្មមួយផ្នែកដែលជួយជំរុញឱ្យមានភាពងាយស្រួលក្នុងការបម្រើរាល់នូវតម្រូវការរបស់សង្គមបច្ចុប្បន្ន។ម្យ៉ាងវិញទៀតការប្រើប្រាស់ខេអេចឃ្យូអរ មានសារៈសំខាន់ដូចជា បង្កើនភាពងាយស្រួល និងសុវត្ថិភាពក្នុងការទូទាត់ បន្ថយការពឹងផ្អែកលើសាច់ប្រាក់ បង្កើនភាពរហ័សនៃប្រតិបត្តិការគាំទ្រដល់ភាពរួមចំណែកនៃសេដ្ឋកិច្ចឌីជីថល ជួយឱ្យអាជីវកម្មតូចមធ្យមទទួលប្រាក់បានយ៉ាងឆាប់រហ័ស និងមានតម្លាភាព ចំណេញពេលវេលា កាត់បន្ថយសាច់ប្រាក់នៅក្នុងដៃ មានហានិភ័យទាប ព្រមទាំងបានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ កាន់តែប្រសើរឡើង។ការប្រើប្រាស់ ខេអេចឃ្យូអរ ជាវិធីសាស្ត្រទូទាត់ប្រព័ន្ធឌីជីថល ត្រូវបានគេពិចារណាថាជាជំហានសំខាន់មួយក្នុងការលើកកម្ពស់ប្រព័ន្ធហិរញ្ញវត្ថុឌីជីថលនៅកម្ពុជា។ ខេអេចឃ្យូអរ ជាឯកសារមានស្តង់ដាដែលបង្កើតឡើងដោយធនាគារជាតិនៃកម្ពុជា ដើម្បីឱ្យប្រព័ន្ធទូទាត់តាម QR របស់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗអាចធ្វើឱ្យស្របគ្នា និងបង្កើនភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋ។

សរុបសេចក្តីមកក្រុមយើងខ្ញុំសូមអធ្យាស្រ័យខន្តីអភ័យទោសពីសំណាក់អ្នកអាន អ្នកសិក្សាស្រាវជ្រាវទាំងអស់ ប្រសិនបើអត្ថបទមួយនេះមានចំណុចខុសឆ្គងដោយប្រការណាមួយនោះ យើងខ្ញុំសូមសំណូមពរជួយផ្តល់នូវការចូលរួមកែលម្អ ដើម្បីឱ្យកិច្ចការស្រាវជ្រាវនេះកាន់តែល្អប្រសើរឡើង មានខ្លឹមសារអត្ថន័យក្បោះក្បាយ សម្រាប់ទុកជាឯកសារដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ស្វែងយល់ពីប្រព័ន្ធបច្ចេកវិទ្យាកាន់តែជំទូលំទូលាយ និងក៏ជាមូលដ្ឋានគ្រឹះក្នុងការសរសេររបាយការណ៍ផ្ចាំបញ្ចប់របស់និស្សិតទាំងអស់ប្រកបដោយភាពជោគជ័យ។

## ៥.២ ការផ្តល់អនុសាសន៍

ដើម្បីជាយុទ្ធសាស្ត្រនៅក្នុងការប្រើប្រាស់ខេអេចឃ្យូអរ ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។ ក្រុមយើងខ្ញុំសូមធ្វើការបញ្ចេញមតិ និងសូមផ្តល់ជាយោបល់នៅក្នុងន័យចូលរួមកែលម្អនូវចំណុចខ្វះខាតទាំងឡាយដើម្បីជួយសម្រួលនិងពង្រឹងការអនុវត្តន៍ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលឱ្យកាន់តែល្អប្រសើរឡើងមួយកម្រិតថែមទៀតដូចជា៖

- បន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃ ខេអេចឃ្យូអរដល់សាធារណជន
- ផ្តល់ការបណ្តុះបណ្តាល និងការជំរុញការប្រើប្រាស់ទៅអាជីវកម្ម

- រៀបចំយុទ្ធនាការលើកទឹកចិត្តឱ្យប្រជាពលរដ្ឋប្រើប្រាស់ប្រព័ន្ធទូទាត់ឌីជីថល
- ផ្តល់ជម្រើសសេវាកម្មដែលងាយស្រួល និងគួរឱ្យទុកចិត្តសម្រាប់អតិថិជន
- ខេអេចឃ្យូអរ មិនមែនគ្រាន់តែជាបច្ចេកវិទ្យាទេ ប៉ុន្តែវាជាជំហានដ៏សំខាន់មួយសម្រាប់ពន្លឿនប្រទេសកម្ពុជាឱ្យទៅរកសេដ្ឋកិច្ចឌីជីថល និងភាពរីកចម្រើនជាសកល។

# ឯកសារយោង : ធនាគារជាតិ នៃកម្ពុជា


- AMS. ការសិក្សាស្រាវជ្រាវនេះគឺត្រូវបានប្រមូលតាមរយៈទិន្នន័យនិងឯកសារផ្សេងៗគេហទំព័រដើម្បីយកមកបកស្រាយទៅលើការប្រើប្រាស់KHQR ប្រភព៖ https://economy.ams.com.kh/
- ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺត្រូវបានប្រមូលតាមបែបគុណវិស័យតាមរយៈទិន្នន័យនិងឯកសារផ្សេងៗដើម្បីយកមកបកស្រាយលើលទ្ធផលនិងផលប្រយោជន៍ដែលទទួលបានមកពីការនៃការប្រើប្រាស់KHQR ប្រភព៖ https://www.kampucheathmey.com/
- ការប្រមូលតាមរយៈទិន្នន័យដែលបានមកពីការចុះកម្មសិក្សានៅធនាគារជាតិដោយផ្ទាល់ដែលមានអាសយដ្ឋាន ផ្លូវ ១០១៩ សង្កាត់ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានី ភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៥ និងគេហទំព័រ https://m.freshnewsasia.com/index.php/en/
- សេចក្តីប្រកាសព័ត៌មានស្តីពីការដាក់ដំណើរការជាផ្លូវការ ខេអេចឃ្យូអរ លេខ ធ១៤-០២២-០០៦ ដកស្រង់ចេញពីគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា National Bank Of Cambodia https://www.nbc.gov.kh/
- ប្រវត្តិ QR Code លោក MASAHIRO HARA ទទួលបន្ទុកការអភិវឌ្ឍ QR Code និងជាអ្នកដែលកំពុងបង្កើតលេខកូដ2D(ប្រភពថ្ងៃទី២០ខែកុម្ភៈឆ្នាំ២០២៣AboutKnowledge) https://youtu.be/RYIHxeq6i4s?si=VfmmwwmTXxXbk_sS
- និយមន័យនិតី ប្រភពថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២៣ https://thmeythmey.com/
- ស្វែងយល់អំពីនិយមន័យ KHQR ប្រភព៖ ការិយាល័យឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ (ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣) https://share.google/6cuVRLCXL0AxlhUR0

# ឧបសម្ព័ន្ធ



# រូបភាពនៃការចុះកម្មសិក្សានៅធនាគារជាតិនៃកម្ពុជា

